ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥......សរ

# សារាចរ
# ស្តីពី
# ការគ្រប់គ្រងផ្សារគ្រប់ប្រភេទនៅទូទាំងប្រទេស

តាមគោលការណ៍ច្បាប់ ផ្សារ និងដីជាទីតាំងនៃផ្សាររបស់រដ្ឋ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន រាជរដ្ឋាភិបាលសម្រេចផ្តល់ជូនអាជីវករនូវសិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផល លើតូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀត ព្រមទាំងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះ ជូនទៅកូនចៅ ឬ អ្នកដទៃទៀតបាន។

អនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងផ្សារនៅទូទាំងប្រទេស អាជីវករលក់ដូរក្នុងផ្សារមានសិទ្ធិ និងកាតព្វកិច្ចបង់ចំណូលចូលថវិការាជធានី ខេត្ត ដែលមានជាអាទិ៍ បង់ភាស៊ី និងបង់ថ្លៃជួល តូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀត តាមការកំណត់នៅក្នុងសៀវភៅបន្ទុក ព្រមទាំងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

រាជរដ្ឋាភិបាលរក្សា និងការពារសិទ្ធិរបស់អាជីវករលក់ដូរក្នុងផ្សារទាំងអស់ តាមគោលការណ៍ស្តីពីការគ្រប់គ្រងផ្សារគ្រប់ប្រភេទនៅទូទាំងប្រទេស ដូចខាងក្រោម៖

## ក- ប្រភេទ និងវិធានគ្រប់គ្រងផ្សារ

ផ្សារត្រូវបានបែងចែកជាប្រភេទ និងគ្រប់គ្រងដោយវិធាន ដូចខាងក្រោម៖

១.ផ្សារប្រភេទ “ក ”: គឺជាផ្សារដែលមានសំណង់ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត ជាអំណោយរបស់រាជរដ្ឋាភិបាល។

២.ផ្សារប្រភេទ “ខ ”: គឺជាផ្សាររបស់រដ្ឋ ដែលត្រូវបានដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីឱ្យវិស័យឯកជនប្រមូលភាស៊ីជារៀងរាល់ឆ្នាំ ពីអាជីវករលក់ដូរស្របតាមការកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។ អាជីវករលក់ដូរទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់ អាស្រ័យផលលើតូប រាន ស្តង់ ឬកន្លែងលក់ដូរដទៃទៀត។

៣.ផ្សារប្រភេទ “គ ”: គឺជាផ្សារដែលវិស័យឯកជនបានអភិវឌ្ឍផ្នែកសំណង់ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀតនៅលើទីតាំងដីរបស់រដ្ឋ។ វិស័យឯកជនត្រូវបានផ្តល់សិទ្ធិឱ្យអភិវឌ្ឍផ្សារប្រភេទនេះ និងអនុញ្ញាតឱ្យរំលស់ទុនវិនិយោគរបស់ខ្លួនសម្រាប់អាណត្តិកំណត់ច្បាស់លាស់ តាមរយៈការប្រមូលចំណូលពីការបង់ភាស៊ី និងពីការបង់ថ្លៃជួលតូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀត ពីអាជីវករលក់ដូរក្នុងផ្សារ តាមការកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។ ទន្ទឹមនេះ អ្នកវិនិយោគមានកាតព្វកិច្ចបង់ចំណូលចូលថវិការាជធានី ខេត្ត តាមការកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។ ក្រោយពេលចប់អាណត្តិ អ្នកវិនិយោគមានកាតព្វកិច្ចប្រគល់សំណង់ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រទាំងអស់មកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

៤.ផ្សារប្រភេទ "ឃ": គឺជាផ្សារដែលមានលក្ខណៈសម្បទាន ដោយក្នុងនោះ វិស័យឯកជនវិនិយោគលើការទិញដី និងលើការសាងសង់ផ្សារ រួមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត។ វិស័យឯកជនត្រូវបានផ្ដល់សិទ្ធិឱ្យអភិវឌ្ឍផ្សារប្រភេទនេះ និងត្រូវចំណាយទុនវិនិយោគរបស់ខ្លួនទាំងស្រុងជាមុនក្នុងការទិញដី ការសាងសង់សំណង់ផ្សារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត ព្រមទាំងអនុញ្ញាតឱ្យរំលស់ទុនវិនិយោគរបស់ខ្លួនសម្រាប់អាណត្តិកំណត់ច្បាស់លាស់តាមរយៈការប្រមូលចំណូលពីការបង់ភាស៊ី និងពីការបង់ថ្លៃជួលតូប រាន ស្តង់ និងកន្លែងលក់ដូរផ្សេងទៀត ពីអាជីវករលក់ដូរក្នុងផ្សារ តាមការកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។ ទន្ទឹមនេះ អ្នកវិនិយោគមានកាតព្វកិច្ចបង់ចំណូលចូលថវិការាជធានី ខេត្ត តាមការកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។ ក្រោយពេលចប់អាណត្តិ អ្នកវិនិយោគមានកាតព្វកិច្ចប្រគល់សំណង់ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រទាំងអស់មកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

**ខ- សិទ្ធិ និងកាតព្វកិច្ចរបស់អាជីវករក្នុងផ្សារ**

អាជីវករដែលមាន តូប រាន ស្តង់ ឬ កន្លែងលក់ដូរផ្សេងទៀតមានសិទ្ធិ និងកាតព្វកិច្ច ទៅតាមប្រភេទផ្សារនីមួយៗ ដូចខាងក្រោម៖

១. ផ្សារប្រភេទ "ក":

- មិនមានកំណត់អាណត្តិលើសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល
- អាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ទៅកូនចៅ ឬ អ្នកដទៃបាន ប៉ុន្តែផ្សារ និងទីតាំងផ្សារជាកម្មសិទ្ធិរបស់រដ្ឋ
- មិនមានកាតព្វកិច្ចបង់ថ្លៃជួល
- បង់ភាស៊ីតាមការកំណត់នៅក្នុងសៀវភៅបន្ទុក និងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

២. ផ្សារប្រភេទ "ខ":

- មិនមានកំណត់អាណត្តិលើសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល
- អាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ទៅកូនចៅ ឬអ្នកដទៃបាន ប៉ុន្តែផ្សារ និងទីតាំងផ្សារ ជាកម្មសិទ្ធិរបស់រដ្ឋ
- មានកាតព្វកិច្ចបង់ថ្លៃជួល
- បង់ភាស៊ីតាមការកំណត់នៅក្នុងសៀវភៅបន្ទុក និងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

៣. ផ្សារប្រភេទ "គ" និង "ឃ":

ចំពោះផ្សារប្រភេទ"គ"និង"ឃ" សិទ្ធិ និងកាតព្វកិច្ចរបស់អាជីវករ ត្រូវបានកំណត់តាមដំណាក់កាល ដូចខាងក្រោម៖

**៣.១ ដំណាក់កាលជាប់ការវិនិយោគរបស់វិស័យឯកជន**

- ត្រូវបានបន្តជូននូវអាណត្តិលើសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល
- អ្នកមានប័ណ្ណកាន់កាប់ តូប រាន ស្តង់ ឬ កន្លែងលក់ដូរផ្សេងទៀត គឺនៅមានសុពលភាពដដែល
- អាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ទៅកូនចៅ ឬ អ្នកដទៃបាន ប៉ុន្តែមិនផ្ដល់កម្មសិទ្ធិជូនទេ
- មានកាតព្វកិច្ចបង់ថ្លៃជួល
- បង់ភាស៊ីតាមការកំណត់នៅក្នុងសៀវភៅបន្ទុក និងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

**៣.២ ដំណាក់កាលក្រោយពីវិស័យឯកជនបានផ្ទេរផ្សារមកជាទ្រព្យសម្បត្តិរដ្ឋ:**

- មិនមានកំណត់អាណត្តិលើសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល
- អាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ទៅកូនចៅ ឬ អ្នកដទៃបាន ប៉ុន្តែផ្សារ និងទីតាំងផ្សារជាកម្មសិទ្ធិរបស់រដ្ឋ
- មានកាតព្វកិច្ចបង់ថ្លៃជួល
- បង់ភាស៊ីតាមការកំណត់នៅក្នុងសៀវភៅបន្ទុក និងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

**គ- វិធានគ្រប់គ្រងការផ្ទេរសិទ្ធិរបស់អាជីវករក្នុងផ្សារ**

ការផ្ទេរសិទ្ធិរបស់អាជីវករក្នុងផ្សារត្រូវបានគ្រប់គ្រងតាមវិធាន ដូចខាងក្រោម÷

- អាជីវករលក់ដូរដែលមានតូប រាន ស្តង់ ឬ កន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ហើយសិទ្ធិនេះអាចផ្ទេរ ទៅកូនចៅ ឬ អ្នកដទៃទៀតបាន ប៉ុន្តែមិនផ្តល់កម្មសិទ្ធិជូនទេ
- សិទ្ធិរបស់អាជីវករត្រូវបានកំណត់ដោយប័ណ្ណសំគាល់សិទ្ធិផ្តល់ជូនដោយសាលារាជធានី ខេត្ត ឬ សាលាក្រុង ស្រុក ខណ្ឌ តាមការប្រតិភូកម្មអំណាចពីសាលារាជធានី ខេត្ត
- សាលារាជធានី ខេត្ត មានសមត្ថកិច្ចផ្តល់ប័ណ្ណសម្គាល់លើ តូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀត និងផ្ទេរសិទ្ធិជូនកូនចៅ ឬ អ្នកដទៃទៀត តាមសំណើរបស់គណៈកម្មការគ្រប់គ្រងផ្សារ។ សាលារាជធានី ខេត្ត អាចធ្វើប្រតិភូកម្មអំណាច តាមស្ថានភាពជាក់ស្តែង ជូនសាលាក្រុង ស្រុក ខណ្ឌ ក្នុងការផ្តល់ប័ណ្ណសម្គាល់នេះ
- ប័ណ្ណសំគាល់ដែលបានផ្តល់ជូនអាជីវករលក់ដូរដែលមានតូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀតរួច ហើយត្រូវមានសុពលភាពជាបន្តទៀត
- ទម្រង់បែបបទសម្រាប់ការផ្តល់ប័ណ្ណសម្គាល់លើ តូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀត និងការផ្ទេរសិទ្ធិ តូប រាន ស្តង់ និងកន្លែងលក់ដូរដទៃទៀតត្រូវកំណត់ដោយគណៈអភិបាលរាជធានី ខេត្ត។

**ឃ- យន្តការគ្រប់គ្រងផ្សារ**

ការគ្រប់គ្រងផ្សារត្រូវអនុលោមតាមយន្តការ ដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាធរមាន។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*

*-គ្រប់សាលារាជធានី-ខេត្ត*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*